**JOINT PRESS RELEASE**
**FOR IMMEDIATE RELEASE**

# ធនាគារ ABA និងក្រុមហ៊ុន តូតាល់កម្ពុជា ចាប់ដៃគូ ផ្តល់សេវាទូទាត់បែបឌីជីថល ដើម្បីបម្រើអតិថិជនអោយកាន់តែប្រសើរជាងមុន

ABA ដែលជាធនាគារពាណិជ្ជឈានមុខគេផ្នែកហិរញ្ញវត្ថុឌីជីថល និងក្រុមហ៊ុនតូតាល់កម្ពុជា ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ TotalEnergies ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ថាមពលធំទូលាយ មានផលិតនិងចែកចាយថាមពលនៅទូទាំងពិភពលោក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូ ដើម្បីបង្កើនបទពិសោធទូទាត់បែបឌីជីថលរបស់អតិថិជនឲ្យកាន់តែសម្បូរបែបនៅតាមស្ថានីយ TotalEnergies ។

ជាមួយការចាប់ដៃគូនេះ អតិថិជន ABA អាចទូទាត់មិនប្រើសាច់ប្រាក់ ដោយស្កេនកូដ QR របស់ ABA PAY  ឬប្រើកាតចរន្តជិត (Contactless) រាល់ពេលចាក់សាំង ឬទិញអីវ៉ាន់នៅតាមស្ថានីយ TotalEnergies ជាង 100 កន្លែងទូទាំងប្រទេស។

លើសពីនេះ ដៃគូអាជីវកម្មរបស់ក្រុមហ៊ុន TotalEnergies ក៏អាចទូទាត់ថ្លៃផលិតផល និងសេវាកម្មនានាតាមកម្មវិធី ABA Mobile ខណៈដែលសមាជិក TotalEnergies Card ក៏អាចបញ្ចូលលុយកាតចាក់សាំងរបស់ខ្លួនដោយប្រើកម្មវិធីធនាគារតាមទូរស័ព្ទដៃនេះបានផងដែរ។

លោក Askhat Azhikhanov នាយកប្រតិបត្តិធនាគារ ABA មានប្រសាសន៍ថា៖ "យើងមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាស ភាពជាដៃគូរបស់យើងជាមួយក្រុមហ៊ុនតូតាល់កម្ពុជា ដើម្បីដាក់ឲ្យប្រើប្រាស់ជម្រើសទូទាត់បែបឌីជីថលជូនអតិថិជន ដៃគូ និងអ្នកចាយចាយ។ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនតូតាល់កម្ពុជា ក៏នឹងប្រើប្រាស់សេវាធនាគារអនឡាញសម្រាប់អាជីវកម្ម ធ្វើជាឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុក្រុមហ៊ុនដ៏ទូលំទូលាយ និងមុខងារគណនីនិម្មិត ដើម្បីដំណើរការប្រតិបត្តិការក្នុងបរិមាណច្រើនៗពីប្រភពផ្សេងៗ និងធ្វើស្វ័យប្រវត្តិកម្ម លើការផ្ទៀងផ្ទាត់ទិន្នន័យ។ យើងជឿជាក់ថា កិច្ចសហការរួមគ្នានេះ នឹងជួយសម្រួលដល់ការរស់នៅបែបទំនើបរបស់អតិថិជន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល"។

លោក Asif Iqbal អគ្គនាយកក្រុមហ៊ុនតូតាល់កម្ពុជា បានមានប្រសាសន៍ថា" យើងមានសេចក្តីសោមនស្សរីករាយដែលបានចាប់ដៃគូជាមួយធនាគារ ABA ដើម្បីជួយសម្រួលដល់ការរស់នៅរបស់អតិថិជនរបស់យើង ដោយផ្តល់ជូននូវដំណោះស្រាយទូទាត់បែបឌីជីថលដែលមានសុវត្ថិភាព កាន់តែងាយស្រួល ប្រសិទ្ធភាព និងចំណាយតិច" ។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មដែលផ្តល់ជូនដោយធនាគារ ABA និងក្រុមហ៊ុន តូតាល់កម្ពុជា សូមទាក់ទងផ្នែកទំនាក់ទំនងរបស់ធនាគារ ABA តាមទូរស័ព្ទលេខ 023 225 333 ឬក្រុមហ៊ុន Total Cambodge តាមទូរស័ព្ទលេខ 023 218 630។

**អំពីក្រុមហ៊ុន តូតាល់កម្ពុជា**

ក្រុមហ៊ុន តូតាល់កម្ពុជា ប្រតិបត្តិការជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ 1993។ ក្រុមហ៊ុន តូតាល់កម្ពុជា ផ្សព្វផ្សាយនៅទូទាំងប្រទេសអំពីផលិតផល និងសេវាកម្មប្រេងឥន្ធនៈផ្សេងៗជាច្រើនដល់អតិថិជនរបស់ខ្លួន ទាំងក្នុងវិស័យឯកជន និងសាធារណៈ។ ក្រុមហ៊ុន តូតាល់កម្ពុជា ផ្តល់ជូននូវផលិតផល និងសេវាកម្ម នៅតាមស្ថានីយជាង 100 កន្លែងសម្រាប់ការចាក់ប្រេងឥន្ធនៈ(ប្រេងសាំង និងម៉ាស៊ូត) ដែលមានហាងទំនិញជាង 52 កន្លែង (ហាង Bonjour) ប្រេងឥន្ធនៈឧស្សាហកម្ម ប្រេងសាំងអាកាសចរណ៍ និងប្រេងម៉ាស៊ីន។ លើសពីនេះ កាត TotalEnergies ជាមធ្យោបាយដ៏ងាយស្រួលក្នុងការជាវ និងគ្រប់គ្រងការជាវប្រេងឥន្ធនៈ។ ក្រុមហ៊ុន តូតាល់កម្ពុជា នៅតែបន្តវិនិយោគលើទីតាំងស្តុកប្រេងស្តង់ដារខ្ពស់សម្រាប់ប្រេងឥន្ធនៈរថយន្ត និងប្រេងឥន្ធនៈអាកាសចរណ៍ផងដែរ។ យើងក៏ផ្តល់សេវាកម្មចាំបាច់ផ្សេងៗ ដូចជា ការវិភាគប្រេង ការដំឡើងស៊ីទែន និងសេវាដឹកជញ្ជូនជូនអតិថិជនពាណិជ្ជកម្មរបស់យើងផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.kh.totalenergies.com ឬwww.facebook.com/TotalEnergiesCambodge

**អំពីធនាគារ ABA**

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខមួយរបស់កម្ពុជា។ គិតត្រឹមថ្ងៃទី 31 ឧសភា 2021 ទ្រព្យសកម្មសរុបរបស់ធនាគារ មានចំនួន 6.9 ប៊ីលានដុល្លារអាមេរិក។ សាខាចំនួន 79, ម៉ាស៊ីនស្វ័យសេវាជាង 600 ទូទាំងប្រទេស, សេវាធនាគារអនឡាញ និងធនាគារតាមទូរស័ព្ទដ៏ទំនើប បានធ្វើឲ្យធនាគារ ABA អាចបម្រើអតិថិជនបានកាន់តែច្រើនឡើងៗជាមួយសេវាហិរញ្ញវត្ថុដ៏ទំនើបសម្បូរបែបទាំងនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.ababank.com ។

ABA គឺជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ មានទ្រព្យសកម្មជាង 273 ប៊ីលានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែមករា ឆ្នាំ2021។ ដោយមានស្នាក់ការកណ្តាលស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ធនាគារជាតិកាណាដាបានពង្រីកសាខានៅស្ទើរតែគ្រប់ខេត្តនៃប្រទេស ជាមួយនឹងអតិថិជនក្នុងដៃ 2.7 លាននាក់។ ធនាគារជាតិកាណាដា ជាគ្រឹះស្ថានហិរញ្ញវត្ថុធំជាងគេលំដាប់ទី 6 ក្នុងប្រទេសកាណាដា និងនាំមុខគេនៅកេប៊ិច ជាទីដែលធនាគារនេះក្លាយជាជម្រើសនៃបណ្តាសហគ្រាសធុនតូច និងមធ្យមនានា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ៖ www.nbc.ca។